ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៣៧០ សហវ

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែ កុម្ភៈ ឆ្នាំ ២០០៣

## ប្រកាសអន្តរក្រសួង
## ស្តីពីការបង្កើតរង្វាន់លើកទឹកចិត្តប្រចាំខែ
## នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា លេខ នស.រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៩ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០, ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ទៃ

-បានឃើញព្រះរាជក្រម លេខ នស/រកម/១២០២/០២១ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣

-បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ

-បានឃើញប្រកាសលេខ ០០៤ សហវ-មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ

-បានឃើញលិខិតលេខ ១១៥ ស ហ វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ

-បានឃើញសារាចរណែនាំលេខ ០០៣ សហវ-ម ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពី រជ្ជទេយ្យបុរេប្រទាន

-បានឃើញប្រកាសលេខ ១២៩ ប្រក-សហវ ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៩៧ ស្តីពីការកំណត់ទឹកប្រាក់រជ្ជទេយ្យបុរេប្រទានជំពូក ១១ សំរាប់ទូទាត់ចំណាយចាំបាច់លើដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច

-បានឃើញតំរូវការចាំបាច់នៃការងារ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

**សំរេច**

**ប្រការ ១ :**

-ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក ១១ នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដើម្បីធ្វើការទូទាត់ការចំណាយទាំងឡាយ ដែលមានចែងក្នុងមាត្រា ៦៤ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ។ ចំនួនទឹកប្រាក់ជាអតិបរិមានៃការចំណាយ ដែលអនុញ្ញាតអោយរជ្ជទេយ្យករបុរេប្រទានធ្វើការទូទាត់ ត្រូវបានកំណត់ក្រោម ៥០០.០០០រ០០ ( ប្រាំរយពាន់រៀលគត់ ) តាមចំណាត់ថ្នាក់ចំណាយនីមួយៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយ នឹង ប្រកាសអន្តរក្រសួង ។ ៧/

**ប្រការ ២ :**

-ចំនួនទឹកប្រាក់នៃរជ្ជទេយ្យបុរេប្រទានជំពូក ១១ សំរាប់មួយជុំ នៃឆ្នាំត្រូវបានកំណត់ត្រឹមចំនួន ៥៣.០២៥.០០០៛០០ ( ហាសិបបីលាន ម្ភៃប្រាំពាន់រៀលគត់ ) ។

**ប្រការ ៣ :**

-សេចក្តីសំរេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤ :**

-អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋានថវិកា នីយកម្ម និង ហិរញ្ញកិច្ច ប្រធាននាយកដ្ឋាន ព្រមទាំងប្រធានគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
[illegible]
[illegible]

រដ្ឋមន្ត្រី
ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់
អ៊ឹម ឈុនលឹម

កន្លែងទទួល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
" ដើម្បីជូនជ្រាប "
- ដូចប្រការ ៤
" ដើម្បីអនុវត្ត "
- ឯកសារ កាលប្បវត្តិ

C:\General Management 2001\Principle's\Prakas Cash advance 2003.doc

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
អគ្គនាយកដ្ឋាន រដ្ឋបាល
នាយកដ្ឋាន ផែនការ សេដ្ឋកិច្ច និង ហិរញ្ញកិច្ច

# ផែនការថវិកា វដ្តទេយ្យបុរេប្រទាន
## ប្រចាំឆ្នាំ ២.០០៣

| ជំពូក | មាត្រា | កថាខណ្ឌ | អនុកថាខណ្ឌ | បរិយាយ | ច្បាប់ អនុម័ត ឆ្នាំ ២.០០៣ | សរុប វដ្តទេយ្យបុរេប្រទាន ប្រចាំឆ្នាំ ២.០០៣ | ១/៨ នៃ វដ្តទេយ្យបុរេប្រទាន | ស្នើសុំបង្កើត វដ្តទេយ្យបុរេប្រទាន ២.០០៣ |
|---|---|---|---|---|---|---|---|---|
| 11 | 01 | 01 | 02 | ការរៀបចំនិងថែទាំ | 350 000 000.00 | 105 000 000.00 | 13 125 000.00 | 13 125 000.00 |
| 11 | 01 | 02 | | ចលនវត្ថុ និង សំភារៈ | 450 000 000.00 | 22 500 000.00 | 2 812 500.00 | 2 812 500.00 |
| 11 | 01 | 04 | | ក្រដាសបោះពុម្ព និង សំភារៈការិយាល័យ | 150 000 000.00 | 60 000 000.00 | 7 500 000.00 | 7 500 000.00 |
| 11 | 01 | 05 | | សៀវភៅមើល និង ឯកសារ | 10 000 000.00 | 6 000 000.00 | 750 000.00 | 750 000.00 |
| 11 | 01 | 06 | | សន្និសិទ្ទ និង ប្រជុំ | 30 000 000.00 | 16 500 000.00 | 2 062 500.00 | 2 062 500.00 |
| 11 | 01 | 07 | 01 | ការថែទាំនិង ដំណើរការ | 20 000 000.00 | 12 200 000.00 | 1 525 000.00 | 1 525 000.00 |
| 11 | 01 | 07 | 03 | សោហ៊ុយជួលរថយន្ត | 5 000 000.00 | 2 500 000.00 | 312 500.00 | 312 500.00 |
| 11 | 01 | 08 | 01 | សោហ៊ុយទទួលភ្ញៀវបរទេស | 20 000 000.00 | 10 000 000.00 | 1 250 000.00 | 1 250 000.00 |
| 11 | 01 | 08 | 02 | សោហ៊ុយទទួលភ្ញៀវជាតិ | 10 000 000.00 | 6 000 000.00 | 750 000.00 | 750 000.00 |
| 11 | 01 | 09 | 01 | បុណ្យជាតិនិងបុណ្យប្រពៃណី | 10 000 000.00 | 5 000 000.00 | 625 000.00 | 625 000.00 |
| 11 | 01 | 09 | 02 | បុណ្យចំរើនព្រះជន្មព្រះមហាកត្សត្រ | 4 000 000.00 | 2 000 000.00 | 250 000.00 | 250 000.00 |
| 11 | 01 | 09 | 04 | បុណ្យផ្សេងៗទៀត | 15 000 000.00 | 7 500 000.00 | 937 500.00 | 937 500.00 |
| 11 | 01 | 13 | | ការឃោសនានិង ផ្សព្វផ្សាយពត៌មាន | 30 000 000.00 | 3 000 000.00 | 375 000.00 | 375 000.00 |
| 11 | 01 | 99 | | ចំណាយផ្សេងៗលើការប្រើប្រាស់ទ្រព្យសម្បត្តិនិង សេវាកម្មនានា | 40 000 000.00 | 24 000 000.00 | 3 000 000.00 | 3 000 000.00 |
| 11 | 02 | 01 | 01 | សោហ៊ុយដឹកជញ្ជូន ក្នុងប្រទេស | 40 000 000.00 | 32 000 000.00 | 4 000 000.00 | 4 000 000.00 |
| 11 | 02 | 01 | 02 | សោហ៊ុយបេសកកម្ម ក្នុងប្រទេស | 50 000 000.00 | 20 000 000.00 | 2 500 000.00 | 2 500 000.00 |
| 11 | 02 | 01 | 03 | សោហ៊ុយស្នាក់នៅ ក្នុងប្រទេស | 180 000 000.00 | 90 000 000.00 | 11 250 000.00 | 11 250 000.00 |
| | | | | **សរុប** | 1414 000 000.00 | 424 200 000.00 | 53 025 000.00 | 53 025 000.00 |

រាជធានីភ្នំពេញ,ថ្ងៃទី 4 ខែ ធ្នូ ឆ្នាំ ២.០០៣

ប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញកិច្ច | ប្រធានការិយាល័យ គណនេយ្យ | អ្នកធ្វើតារាង

អ៊ឹម សុខលីម

Sheets of Budget 2003